# សេចក្តីណែនាំ

## ស្តីពី

# ការគ្រប់គ្រងសំណល់កក់នៅតាម
# រោងចក្រ-សហគ្រាស

**ព្រះរាជាណាចក្រកម្ពុជា**

ជាតិ សាសនា ព្រះមហាក្សត្រ

គណៈរដ្ឋមន្ត្រី

ក្រសួងបរិស្ថាន

លេខ: 177 ប.ស្ល [illegible]

រាជធានីភ្នំពេញ. ថ្ងៃទី ០១ ខែ ១៣ ឆ្នាំ ២០០០

## សេចក្តីណែនាំ

### ស្តីពី ការគ្រប់គ្រងសំណល់គក់នៅតាមរោងចក្រ-សហគ្រាស

**យោង** : - ព្រះរាជក្រមលេខ នស/ រកម/ ១២៩៦/ ៣៦ ចុះថ្ងៃទី ២៤ ខែធ្នូ ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពី កិច្ចការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ ។

- អនុក្រឹត្យលេខ ២៧ អនក្រ/ បក ចុះថ្ងៃទី ០៦ ខែមេសា ឆ្នាំ១៩៩៩ របស់រាជរដ្ឋាភិបាល ស្តីពី ការត្រួតពិនិត្យការបំពុលទឹក ។
- អនុក្រឹត្យលេខ ៣៦ អនក្រ/ បក ចុះថ្ងៃទី ២៧ ខែមេសា ឆ្នាំ១៩៩៩ របស់រាជរដ្ឋាភិបាល ស្តីពី ការគ្រប់គ្រងសំណល់រឹង។

ដោយពិនិត្យឃើញថា នៅតាមបណ្តារោងចក្រ-សហគ្រាសបោកគក់សំលៀកបំពាក់ ការគ្រប់គ្រងនូវសំណល់ភក់នៃអាងស្តុក និងអាងប្រព្រឹត្តកម្មសំអាតសំណល់រាវរបស់ខ្លួន គឺមានលក្ខណៈពុំទាន់សមស្របទៅតាមលក្ខណៈបច្ចេកទេស ដែលអាចធានាបាននូវសុវត្ថិភាពបរិស្ថាន ហើយកន្លងមកនេះ មានរោងចក្រមួយចំនួនបានបូម ឬស្តារសំណល់ភក់ទាំងនោះ ដឹកយកទៅចាក់ចោលនៅតាមទីវាល និងតំបន់ទឹកសាធារណៈ ដែលជាហេតុបង្កអោយមានការបំពុលបរិស្ថាន និងប៉ះពាល់ទៅដល់សុខភាពសាធារណៈនាពេលបច្ចុប្បន្ននិងទៅអនាគត ។

ដើម្បីជំរុញការគ្រប់គ្រងសំណល់ភក់នៅតាមបណ្តារោងចក្របោកគក់ ឱ្យមានលក្ខណៈសមស្របទៅតាមលក្ខណៈបច្ចេកទេសសុវត្ថិភាពបរិស្ថាន ដែលអាចធានានូវការទប់ស្កាត់និងកាត់បន្ថយការបំពុលបរិស្ថាន និងការពារសុខភាពសាធារណៈ ក្រសួងបរិស្ថានសូមធ្វើការណែនាំដល់បណ្តារោងចក្រ-សហគ្រាសបោកគក់សំលៀកបំពាក់ទាំងអស់ ដូចខាងក្រោម :

១ - ត្រូវធ្វើការផ្តល់ដំណឹងជូនមកក្រសួងបរិស្ថានជាមុន ក្នុងករណីដែលរោងចក្រ-សហគ្រាសបោកគក់សំលៀកបំពាក់ មានគំរោងធ្វើការស្តារសំណល់ភក់ចេញពីអាងស្តុក ឬអាងប្រព្រឹត្តកម្មសំអាតសំណល់រាវរបស់ខ្លួន ។

២ - ត្រូវធ្វើការហាល ឬគៀបសំងួតសំណល់ភក់ នៃអាងស្តុកនិងអាងប្រព្រឹត្តកម្មសំអាតសំណល់រាវ ចោកគក់ និងត្រូវធ្វើការស្តុកទុកជាបណ្តោះអាសន្នឱ្យបានសមស្រប ជៀសវាងការប៉ះពាល់ដល់គុណភាពបរិស្ថាននិងសុខភាពសាធារណៈ ។

៣ - ត្រូវធ្វើរបាយការណ៍ពីបរិមាណស្តុកនៃសំណល់ភក់ និងទីតាំងស្តុក មកក្រសួងបរិស្ថានរៀងរាល់បីខែម្តង ។

៤ - ហាមឃាត់ដាច់ខាតការចាក់ចោល ឬដឹកសំណល់ភក់លាយឡំជាមួយសំណល់រឹងលំនៅស្ថាន។

៥ - ហាមឃាត់ដាច់ខាតការបូមសំណល់ភក់ នៃអាងស្តុកនិងអាងប្រព្រឹត្តកម្មសំអាតសំណល់រាវ ចោកគក់ យកទៅចាក់ចោលនៅតាមលូសាធារណៈ ឬតំបន់ទឹកសាធារណៈ ។

៦ - ត្រូវធ្វើការសុំអនុញ្ញាតពីក្រសួងបរិស្ថាន មុននឹងធ្វើការដឹកជញ្ជូនសំណល់ភក់ស្ងួតយកចេញពីទីតាំងរោងចក្រ-សហគ្រាស ទៅកាន់ទីដីនៃក្នុងគោលបំណងណាមួយ ។

ទទួលបានសេចក្តីណែនាំនេះ ម្ចាស់រោងចក្រ-សហគ្រាសចោកគក់សំលៀកបំពាក់ទាំងអស់ត្រូវខិតខំអនុវត្តការគ្រប់គ្រងសំណល់ភក់នៃអាងស្តុក និងអាងប្រព្រឹត្តកម្មសំអាតសំណល់រាវរបស់ខ្លួនប្រកបដោយប្រសិទ្ធខ្ពស់ ។ ក្នុងករណីមិនអនុវត្តតាម ឬអនុវត្តផ្ទុយទៅនឹងចំនុចណាមួយនៃសេចក្តីណែនាំខាងលើ ក្រសួងបរិស្ថាននឹងចាត់វិធានការតាមផ្លូវច្បាប់ ។ chs

រដ្ឋមន្ត្រី

<u>ចំលងជូន</u>

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងមហាផ្ទៃ
- ក្រសួងឧស្សាហកម្ម រ៉ែនិងថាមពល
- សាលាខេត្ត-ក្រុង

" <u>ដើម្បីជូនជ្រាបជាព័ត៌មាន</u> "

- អគ្គនាយកដ្ឋាន
- នាយកដ្ឋានត្រួតពិនិត្យការបំពុលបរិស្ថាន

" <u>ដើម្បីមុខការ</u> "

- មន្ទីរបរិស្ថានខេត្ត-ក្រុង " <u>ដើម្បីសហការតាមដានការអនុវត្តន៍</u> "
- ឯកសារ កាលប្បវត្តិ